ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
លេខៈ ០៤៥ ទ.ក.ស.ណ

# សេចក្ដីជូនដំណឹង
# ស្ដីពី មហាសន្និបាតភាគហ៊ុនិក លើកទី១៤
# របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនធម្មតារបស់ រ.ទ.ស.ភ ទាំងអស់មេត្តាជ្រាបថាៈ អនុលោមតាមសេចក្ដីសម្រេចនៅក្នុងកិច្ចប្រជុំលើកទី១ របស់ក្រុមប្រឹក្សាភិបាល អាណត្តិទី៩ នាថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៦ រ.ទ.ស.ភ នឹងរៀបចំមហាសន្និបាតភាគហ៊ុនិកសាមញ្ញ លើកទី១៤ **នៅថ្ងៃសុក្រ ១៣កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៦** ចាប់ពីវេលាម៉ោង ៨:០០នាទីព្រឹក នៅទីស្នាក់ការ រ.ទ.ស.ភ និងតាមរយៈប្រព័ន្ធអនឡាញ (Zoom) ដែលមានរបៀបវារៈដូចខាងក្រោមៈ

១. ការចុះវត្តមាន
២. ប្រកាសហេតុ
៣. បទបង្ហាញស្ដីពីៈ
   ក. របាយការណ៍លទ្ធផលអាជីវកម្មឆ្នាំ២០២៥
   ខ. ទិសដៅអាជីវកម្មឆ្នាំ២០២៦
   គ. សំណួរ និងចម្លើយ
៤. កម្មវិធីបោះឆ្នោតតាមប្រព័ន្ធអនឡាញ លើកម្មវត្ថុចំនួន២ៈ
   ក. ការបោះឆ្នោតអនុម័តបែងចែកភាគលាភជូនភាគហ៊ុនិក
   ខ. ការបោះឆ្នោតអនុម័តលាភការរបស់ក្រុមប្រឹក្សាភិបាល
៥. មតិបញ្ចប់ និងសេចក្ដីថ្លែងអំណរគុណរបស់ប្រធានគណៈអធិបតី

ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនធម្មតារបស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះភាគហ៊ុនិក **នាថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៦** (កាលបរិច្ឆេទកំណត់ទុកនៃមហាសន្និបាតភាគហ៊ុនិក លើកទី១៤) ត្រូវបញ្ជាក់ការចូលរួមជាមួយ ធនាគារ អេស៊ីលីដា ភីអិលស៊ី (ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់) នៅរៀងរាល់ថ្ងៃធ្វើការ ចាប់ពី **ថ្ងៃទី០៨ ដល់ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៦** ចាប់ពីម៉ោង ៨:០០នាទីព្រឹក ដល់ម៉ោង ១៦:៣០នាទីរសៀល។

* **បញ្ជាក់ ៖**

១. ភាគហ៊ុនិកដែលមានសិទ្ធិចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិក គឺជាភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះផ្លូវការដែលទទួលបានពីបញ្ជីឈ្មោះភាគហ៊ុនិកដែលរៀបចំឡើងនៅ **ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៦**។
២. ភាគហ៊ុនិកដែល**លក់** មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅ **ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៦** (កាលបរិច្ឆេទអិចរាយថ៍ / Ex-Right) គឺ **នៅតែមានសិទ្ធិ**ចូលរួម និងបោះឆ្នោតក្នុងមហាសន្និបាត។
៣. ភាគហ៊ុនិកដែល**ទិញ** មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅ **ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៦** (កាលបរិច្ឆេទអិចរាយថ៍ / Ex-Right) គឺ **មិនមានសិទ្ធិ**ចូលរួម និងបោះឆ្នោតក្នុងមហាសន្និបាតឡើយ។



អគារ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទៈ (៨៥៥) ៣១ ៩៣៥ ៨០ ៨០ Email: admin@ppwsa.com.kh

៤. ភាគហ៊ុនិកដែលមានសិទ្ធិចូលរួមមហាសន្និបាតភាគហ៊ុនិកលើកទី១៤ របស់ រ.ទ.ស.ភ ប៉ុន្តែមិនបានធ្វើការបញ្ជាក់ការចូលរួមរបស់ខ្លួនជាមួយ ធនាគារ អេស៊ីលីដា ភីអិលស៊ី តាមការកំណត់ខាងលើនេះ នឹងមិនអនុញ្ញាតឱ្យចូលរួមបោះឆ្នោតក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី១៤ របស់ រ.ទ.ស.ភ នោះទេ។

៥. ភាគហ៊ុនិកអាចចូលរួមមហាសន្និបាតនេះ ដោយផ្ទាល់ ឬតាមរយៈអាណត្តិគាហកៈ (អ្នកតំណាង)។ ភាគហ៊ុនិកដែលចូលរួមតាមរយៈអាណត្តិគាហកៈ ត្រូវតែងតាំងអាណត្តិគាហកៈរបស់ខ្លួនតាមទម្រង់ "លិខិតតែងតាំងអាណត្តិគាហកៈ (អ្នកតំណាង)" ដែលផ្តល់ដោយ រ.ទ.ស.ភ ឬ ធនាគារ អេស៊ីដា ភីអិលស៊ី ដោយត្រូវផ្តល់លិខិតតែងតាំងអាណត្តិគាហកៈនេះមក រ.ទ.ស.ភ តាមរយៈសារអេឡិចត្រូនិច ir@ppwsa.com.kh យ៉ាងយូរត្រឹម**ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៦** ដើម្បីចូលរួម និងបោះឆ្នោតនៅក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី១៤ របស់ រ.ទ.ស.ភ។

៦. រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមរក្សាសិទ្ធិកែប្រែកម្មវិធី របៀបវារៈ និងទម្រង់អនឡាញនៃមហាសន្និបាតភាគហ៊ុនិកលើកទី១៤ របស់ រ.ទ.ស.ភ ក្នុងករណីមានការចាំបាច់។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងទៅកាន់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ តាមអាសយដ្ឋាន និងលេខទំនាក់ទំនងដូចខាងក្រោម៖

- **ធនាគារ អេស៊ីលីដា ភីអិលស៊ី**
  អាសយដ្ឋាន : អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
  - **លោកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ**
    ទូរស័ព្ទ : (៨៥៥) ៧០ ៥០០ ៣៧៧
    អ៊ីម៉ែល : samreth.vannybopharath@acledabank.com.kh
  - **លោក កែន រិទ្ធពុទ្ធា**
    ទូរស័ព្ទ : (៨៥៥) ១៥ ៨០០ ៦៦៣
    អ៊ីម៉ែល : ken.rithputhea@acleda.com.kh
  - **កញ្ញា ចាន់ ទេពកញ្ញា**
    ទូរស័ព្ទ : (៨៥៥) ១៦ ២៩៥ ៤៣២
    អ៊ីម៉ែល : op.rtp@acledabank.com.kh
- **រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
  - អាសយដ្ឋាន : អាគារ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
  - ទូរស័ព្ទ : (៨៥៥) ៣១ ៣២២ ៦៣៤៥
  - អ៊ីម៉ែល : ir@ppwsa.com.kh

ថ្ងៃអង្គារ ១៤រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៦
**អគ្គនាយក**

**អ៊ឹន សាភាន**

**ចម្លងជូន៖**
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- និយ័តករមូលបត្រកម្ពុជា
- ប្រធាន និងគ្រប់សមាជិកក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ
- មន្ត្រីត្រួតពិនិត្យរដ្ឋអម រ.ទ.ស.ភ

*"មេត្តាជ្រាប"*
- ឯកសារ-កាលប្បវត្តិ